**សលាកប័ត្រព័ត៌មាន ៖** បម្រាមលើការជួបប្រជុំ ការដើរក្បួន និងបាតុកម្មនៅកម្ពុជា

**ពេលវេលា ៖** ខែមករា ឆ្នាំ២០១៤

**ទិដ្ឋភាពរួម ៖** ការសម្រេចចិត្តនាពេលថ្មីៗនេះរបស់រាជរដ្ឋាភិបាលកម្ពុជា (រដ្ឋាភិបាល) ក្នុងការដាក់ចេញនូវបម្រាមដោយគ្មានពេលកំណត់ទៅលើរាល់ការធ្វើបាតុកម្ម ការប្រមូលផ្តុំ ឬការដើក្បួន គឺជាការអនុវត្តន៍មិនសមាមាត្រ និងរំលោភលើសិទ្ធិសេរីភាពការជួបប្រជុំដោយសន្តិវិធី។ គួបផ្សំនឹងការប្រើប្រាស់កម្លាំងហួសហេតុរបស់កងកម្លាំងរក្សាសន្តិសុខ ទៅលើក្រុមបាតុករ បញ្ហានេះត្រូវបានចាត់ទុកថាជាការធ្វើឲ្យស្ថានភាពសិទ្ធិមនុស្សនៅព្រះរាជាណាចក្រកម្ពុជា (កម្ពុជា) ធ្លាក់ដុនដាប។

## សេចក្តីផ្តើម

សលាកប័ត្រព័ត៌មាននេះបង្ហាញពីទិដ្ឋភាពរួម នៃការរឹតបន្តឹងលើសិទ្ធិសេរីភាពនៃការជួបប្រជុំដោយសន្តិវិធីនៅកម្ពុជា ថ្វីបើត្រូវបានការការពារដោយរដ្ឋធម្មនុញ្ញកម្ពុជា ច្បាប់ជាតិ និងច្បាប់អន្តរជាតិ យ៉ាងណាក៏ដោយ។ រដ្ឋាភិបាលតែងតែរឹតបន្តឹងសិទ្ធិរបស់ប្រជាពលរដ្ឋខ្លួនក្នុងការជួបប្រជុំ។ បម្រាមនាពេលថ្មីៗទៅលើរាល់ការជួបប្រជុំ ការដើរក្បួន និងបាតុកម្ម ក្នុងការឆ្លើយតបទៅនឹងការធ្វើបាតុកម្មរបស់គណបក្សប្រឆាំង និងក្រុមកម្មកររោងចក្រ គឺជាជំហានថ្មីបំផុតមួយដែលបានបំពានមកលើសិទ្ធិនេះ។

សលាកប័ត្រព័ត៌មាននេះតាក់តែងឡើងដោយ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») ដែលជាអង្គការមិនមែនរដ្ឋាភិបាល មិនចូលបក្សសម្ព័ន្ធ និងឯករាជ្យដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

## សាវតារករណី

នៅថ្ងៃទី៤ ខែមករា ឆ្នាំ២០១៤ ក្រសួងមហាផ្ទៃបានចេញសេចក្តីថ្លែងការណ៍បញ្ជាក់ថា នឹងមានការហាមឃាត់ដោយគ្មានកំណត់ទៅលើការបាតុកម្ម ការជួបជុំ ឬការដើរក្បួន នាពេលខាងមុខ រហូតដល់ «សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខត្រូវបានស្តារឡើងវិញ»។ សាលារាជធានីភ្នំពេញ ក៏បានផ្ញើលិខិតមួយជូនដល់លោក សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិកម្ពុជា (គ.ស.ជ) បដិសេធចំពោះលិខិតជូនដំណឹងរបស់បាតុកម្មនាពេលខាងមុខរបស់ គ.ស.ជ ហើយបញ្ជាក់ថា គ.ស.ជ នឹងមិនអនុញ្ញាតឲ្យធ្វើការដើរក្បួន ឬបាតុកម្មទៀតនោះទេ លុះត្រាណាតែសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈត្រូវបានធានា។ បន្ថែមពីលើនោះ សារព័ត៌មានកោះសន្តិភាពបានរាយការណ៍កាលពីថ្ងៃទី៦ ខែមករា ថា អភិបាលខណ្ឌឫស្សីកែវ នៅទីក្រុងភ្នំពេញ បានអំពាវនាវឲ្យមន្ត្រីនគរបាល បំបែករាល់ការប្រមូលផ្តុំទាំងឡាយណាដែលមានចំនួនមនុស្សលើសពី ១០ នាក់។

បម្រាមនេះត្រូវបានអនុវត្តនៅក្នុងបរិបទនៃការជាប់គាំងផ្នែកនយោបាយ ៖ ចាប់តាំងពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នា ខែកក្កដា ឆ្នាំ២០១៣ មក គ.ស.ជ បានធ្វើពហិការក្នុងការចូលរួមជាមួយរដ្ឋសភា ដោយសារតែមានភាពមិនប្រក្រតីនៅក្នុងការបោះឆ្នោត និងការរៀបចំធ្វើមហាបាតុកម្មជាទៀងទាត់។ ថ្មីៗនេះ កម្ពុជាបានក្លាយទៅជាកន្លែងដែលមានការបង្ក្រាបដោយហិង្សា ពីសំណាក់កងកម្លាំងសន្តិសុខ ទៅលើការធ្វើបាតុកម្មរបស់ គ.ស.ជ និងក្រុមកម្មកររោងចក្រ ដែលក្រុមកម្មកររោងចក្រធ្វើការតវ៉ាដើម្បីទាមទារតម្លើងប្រាក់ឈ្នួលគោលអប្បបរមា។ ការបង្ក្រាប បាន

បណ្ដាលឲ្យមនុស្សយ៉ាងហោចណាស់ ៥ នាក់ បានបាត់បង់ជីវិត និងមនុស្សជាច្រើនត្រូវរងរបួស និងមានការចាប់ឃាត់ខ្លួនមនុស្សចំនួន ២៣ នាក់ ផងដែរ។

បម្រាមនេះត្រូវបានសាកល្បងធ្វើនៅថ្ងៃទី៦ ខែមករា ឆ្នាំ២០១៤ ដោយបានឃាត់ខ្លួនសកម្មជនបឹងកក់ចំនួន ៥ នាក់ ជាបណ្ដោះអាសន្ន ពេលដែលពួកគាត់មានបំណងយកញត្តិទៅដាក់នៅស្ថានទូតបារាំង ដើម្បីស្នើសុំឲ្យមានការដោះលែង បាតុករអហិង្សាចំនួន ១០ នាក់ ដែលត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី២ ខែមករា ឆ្នាំ២០១៤។ ផ្ទុយមកវិញ គណបក្សកាន់អំណាច គឺគណបក្សប្រជាជន (ប្រ.ជ) បានរៀបចំ «ទិវាជ័យជំនះ» ដើម្បីរំលឹកខួបថ្ងៃផ្ដួលរំលំរបបខ្មែរក្រហម នាថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ដែលបានយកឈ្នះលើរបបខ្មែរក្រហម ជាព្រឹត្តិការណ៍ដែលមានអ្នកគាំទ្រ ប្រ.ជ រាប់ពាន់នាក់ចូលរួម ដែលនេះគឺជាទង្វើផ្ទុយទៅនឹងបម្រាមរបស់រដ្ឋាភិបាលផ្ទាល់ទៅលើការជួបប្រជុំ។ ម្យ៉ាងវិញទៀត នៅថ្ងៃទី៩ ខែមករា ឆ្នាំ២០១៤ ក្រុមយុវជនសកម្មជនរបស់ គ.ស.ជ ចំនួន ៩ នាក់ ត្រូវបានសន្តិសុខសាលារាជធានី និងកងរាជអាវុធហត្ថបំបែកពីទីលានប្រជាធិបតេយ្យ។

## សិទ្ធិសេរីភាពនៃការជួបប្រជុំដោយសន្តិវិធី

សិទ្ធិសេរីភាពនៃការជួបប្រជុំដោយសន្តិវិធី ត្រូវបានលើកកម្ពស់ និងការពារដោយមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា («រដ្ឋធម្មនុញ្ញ») ដែលចែងថាប្រជាពលរដ្ឋខ្មែរត្រូវមាន *«សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន ការបោះពុម្ពផ្សាយ និងការជួបប្រជុំ»* ។ បន្ថែមពីលើនោះ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញបានបញ្ចូលសេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្ស និងអនុសញ្ញា និងកតិកាសញ្ញាអន្តរជាតិ ដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស រួមទាំងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ក.អ.ស.ព.ន) ទៅក្នុងច្បាប់ជាតិ ដែលកម្ពុជាបានផ្ដល់សច្ចាប័ននៅក្នុង ឆ្នាំ១៩៩២។ ការអនុវត្តច្បាប់អន្តរជាតិដោយផ្ទាល់នៅក្នុងតុលាការកម្ពុជានេះ ត្រូវបានបញ្ជាក់បន្ថែមដោយសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ ឆ្នាំ២០០៧។

សិទ្ធិសេរីភាពនៃការជួបប្រជុំដោយសន្តិវិធី គឺត្រូវបានការពារ ក្នុងមាត្រា ២១ នៃ ក.អ.ស.ព.ន។ មាត្រា ២១ នៃ ក.អ.ស.ព.ន បានចែងពីសេចក្ដីណែនាំនៃការរឹតបន្តឹងទៅលើសេរីភាពនៃ ការជួបប្រជុំដែលអាចទទួលយកបាន ដោយបញ្ជាក់ថា *«មិនមានការរឹតបន្តឹងណាត្រូវបានដាក់មកលើការអនុវត្តសិទ្ធិនេះ លើកលែងតែការរឹតបន្តឹងដែលមានចែងនៅក្នុងច្បាប់ និងដែលមានលក្ខណៈចាំបាច់»* ដើម្បីជានា *«សន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្ដាប់ធ្នាប់សាធារណៈ ការការពារសុវត្ថិភាពសាធារណៈ ឬសីលធម៌ ឬការការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ»* ។ ការរឹតបន្តឹងលើសិទ្ធិសេរីភាពការជួបប្រជុំ ត្រូវបានអនុញ្ញាតក្នុងកាលៈទេសៈដ៏ចង្អៀតបំផុតតែប៉ុណ្ណោះ ហើយគួរតែត្រូវសមាមាត្រនឹងគោលបំណងនៃការរឹតបន្តឹងនោះ។ បន្ថែមពីលើនោះ មាត្រា ៣៥ នៃរដ្ឋធម្មនុញ្ញចែងថា ប្រជាពលរដ្ឋខ្មែរទាំងអស់មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយរបស់ប្រទេសជាតិ។ ប៉ុន្តែ ការអនុវត្តន៍នៃបម្រាមនេះ កាន់តែរាំងបន្ថែមទៀតដល់សិទ្ធិទាំងនេះ។

## សេចក្ដីសន្និដ្ឋាន

បម្រាមទាំងស្រុងនាពេលថ្មីៗនេះ ទៅលើការជួបប្រជុំទាំងអស់នៅកម្ពុជា គឺមានលក្ខណៈមិនសមាមាត្រ និងលើសលប់ខ្លាំង ដោយសារតែមិនមានការកំណត់ពេលវេលាជាក់លាក់ និងបានហាមឃាត់រាល់ការធ្វើបាតុកម្ម ការជួបប្រជុំ និងការដើរក្បួនទាំងអស់នៅកម្ពុជា។ បម្រាមណាមួយគួរតែមានកំណត់ពេលវេលាជាក់លាក់ ជាជាងធ្វើឡើងដោយផ្អែកទៅលើការវាយតម្លៃដែលមិនអាចវាស់វែងបានដូចជា «សណ្ដាប់ធ្នាប់ និងសុវត្ថិភាពសាធារណៈ» នឹងត្រូវបានស្ដារឡើង

វិញនោះទេ។ ឧទាហរណ៍ ការហាមឃាត់រយៈពេល ៤៨ ម៉ោង អាចគ្រប់គ្រាន់ និងអាចទទួលយកបានសម្រាប់ស្តារនូវសន្តិសុខ។ ប៉ុន្តែ បម្រាមនោះបានដាក់ចេញរយៈពេល ៧ ថ្ងៃ មកហើយ។ មួយវិញទៀត ហាក់ដូចជាមានការពិបាកក្នុងការផ្ទៀងផ្ទាត់ និងហាក់ដូចជាវិធានការហួសហេតុ ក្នុងការហាមឃាត់រាល់ការធ្វើបាតុកម្ម ការជួបជុំ និងការដើរក្បួន នៅក្នុងប្រទេសទាំងមូល ខណៈពេលដែលការធ្វើបាតុកម្ម គឺគ្រាន់តែប៉ះពាល់ដល់តំបន់មួយចំនួននៅទីក្រុងភ្នំពេញតែប៉ុណ្ណោះ។ ដូច្នេះ នេះបញ្ជាក់ច្បាស់ថាការហាមឃាត់ដ៏ទូលាយមកលើការជួបប្រជុំបែបនេះ ត្រូវបានជំរុញដោយឆន្ទៈនយោបាយ និងគ្រាន់តែបម្រើគោលបំណងការពាររដ្ឋាភិបាលបច្ចុប្បន្ន ពីការរិះគន់ពីសំណាក់កម្មកររោងចក្រ និងគណបក្សប្រឆាំងតែប៉ុណ្ណោះ។

ម.ស.ម.ក ជឿជាក់ថាបម្រាមដែលគ្មានពេលកំណត់ ទៅលើរាល់ការធ្វើបាតុកម្ម ការដើរក្បួន និងការជួបជុំ គឺជាវិធានការអសមាមាត្រ និងមានលក្ខណៈលើសលុប ដូច្នេះ នេះជាការរំលោភបំពានមកលើបញ្ញត្តិជាតិ និងអន្តរជាតិដែលបានការពារសិទ្ធិការជួបប្រជុំដោយសន្តិវិធី។ ជាមួយនឹងបម្រាមបែបគ្រប់ដណ្តប់ទាំងអស់ និងការប្រើប្រាស់កម្លាំងច្រើនហួសហេតុពីសំណាក់កងកម្លាំងសន្តិសុខមកលើក្រុមបាតុករនេះ រដ្ឋាភិបាលគឺកំពុងតែធ្វើសារយ៉ាងច្បាស់ទាក់ទិននឹងសេរីភាពក្នុងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋកម្ពុជាថា ៖ មានលំហតិចតួចណាស់ ចំពោះទស្សនៈដែលផ្ទុយពីទស្សនៈរបស់គណបក្សកាន់អំណាច។ ម.ស.ម.ក សូមអំពាវនាវឲ្យរដ្ឋាភិបាល និរាករណ៍បម្រាមថ្មីនេះ ចំពោះការជួបប្រជុំ ការដើរក្បួន និងការធ្វើបាតុកម្មទាំងអស់នៅកម្ពុជា និងចាត់វិធានការដើម្បីធានាថាការរឹតបន្តឹងចំពោះសេរីភាពនៃការជួបប្រជុំបែបនោះ គួរត្រូវតែហាមឃាត់នាពេលអនាគត។

**សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង កញ្ញា សន រ៉ាមណា តាមរយៈទូរសព្ទ +៨៥៥ (០) ១៧ ៦៥៥ ៥៩១ ឬ អ៊ីម៉ែល ramanasorn@cchrcambodia.org ឬជូលៀត រូសឺឡូត តាមរយៈទូរសព្ទ +៨៥៥ (០) ១៥ ៣៥០ ៦២០ ឬ អ៊ីម៉ែល julietterousselot@cchrcambodia.org ។**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

BY NC SA